**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**គណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា**


**ប្រធានគណៈមេធាវី**

មេធាវី ប៊ុន ហុន

**ក្រុមប្រឹក្សាគណៈមេធាវី**

១-មេធាវី សាំង វណ្ណៈ
២-មេធាវី អ៊ុំ ភិរិយា
៣-មេធាវី កែត ឃី
៤-មេធាវី អ៊ឹម ប៊ុលី
៥-មេធាវី ខៀវ សំបូរ
៦-មេធាវី ជា សុភន្ទួន
៧-មេធាវី សាន់ ជួយ
៨-មេធាវី ថាន ផានិត
៩-មេធាវី ជូ ចាន់ធីរ៉ា
១០-មេធាវី កេង សុម៉ាឡា
១១-មេធាវី ម៉ី ឧសភា
១២-មេធាវី សេង សុខឃីម
១៣-មេធាវី លីវ សុវណ្ណា
១៤-មេធាវី ឈឹម តិរម្យ
១៥-មេធាវី សំ សុគង់
១៦-មេធាវី នង មានន្ទ
១៧-មេធាវី អ៊ូ ឌីតាពៅ
១៨-មេធាវី លី ពីង
១៩-មេធាវី យឹម វិស្សុត
២០-មេធាវី លឹម ច័ន្ទលីដា
២១-មេធាវី កែ វិសាល
២២-មេធាវី ហូ លីហួរ
២៣-មេធាវី វ៉ា ពិសី
២៤-មេធាវី ជា ហុងរី
២៥-មេធាវី សៅ កញ្ញា
២៦-មេធាវី ម៉ុន វិមានចំប៉ា
២៧-មេធាវី ឈី សម្បត្តិ


លេខ : ៣១១ /សសគម/១៦

រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែមករា ឆ្នាំ២០១៦

# សេចក្ដីសម្រេច

## ស្ដីពី

## ការអនុញ្ញាតឱ្យប្ដូរគ្រូកម្មសិក្សា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨៩៥/០៦ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ១៩៩៥ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីលក្ខន្តិកៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញបទបញ្ជាផ្ទៃក្នុងគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ១៩៩៥
- បានឃើញក្រមសីលធម៌មេធាវីនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១២
- បានឃើញកំណត់ហេតុនៃមហាសន្និបាតគណៈមេធាវី ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៤ ស្ដីពីការបោះឆ្នោតជ្រើសតាំងលោកមេធាវី **ប៊ុន ហុន** ជាប្រធានគណៈមេធាវីអាណត្តិទី ១០
- បានឃើញកំណត់ហេតុនៃមហាសន្និបាតគណៈមេធាវី ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៥ ស្ដីពីការបោះឆ្នោតជ្រើសតាំងសមាជិក-សមាជិកាក្រុមប្រឹក្សាគណៈមេធាវីអាណត្តិទី ៨
- បានឃើញសេចក្ដីសម្រេចលេខ ៤១៨/សសគម/១៥ ចុះថ្ងៃទី០៨ ខែតុលា ឆ្នាំ២០១៥ របស់គណៈមេធាវី ស្ដីពីការអនុញ្ញាតឱ្យចូលប្រកបវិជ្ជាជីវៈជាមេធាវីកម្មសិក្សា
- យោងតាមសំណើរបស់សាមីខ្លួន ចុះថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០១៥
- យោងតាមការសម្រេចរបស់ក្រុមប្រឹក្សាគណៈមេធាវី នាសម័យប្រជុំថ្ងៃទី១៥ ខែមករា ឆ្នាំ២០១៦។

## ស ម្រេ ច

**ប្រការ ១.-** អនុញ្ញាតឱ្យលោកមេធាវី **ទូច ឆេងភាំង** អត្តលេខ **១១៣៣ T** ប្ដូរគ្រូកម្មសិក្សាពីលោកមេធាវី **ទូច ឆេងតិច** មកលោកស្រីមេធាវី **ទូច សុទ្ធារី** វិញ ដែលមានការិយាល័យឈ្មោះ **ការិយាល័យមេធាវី ទូច ឆេងតិច** មានអាសយដ្ឋានស្ថិតនៅ**ផ្ទះលេខ ១២៨ ផ្លូវលេខ ៤៣០ ក្រុមទី ២ សង្កាត់ទំនប់ទឹក ខណ្ឌចំការមន រាជធានីភ្នំពេញ** ចាប់ពីថ្ងៃចេញសេចក្ដីសម្រេចនេះតទៅ។


អគារស្ថិតនៅកាច់ជ្រុងផ្លូវលេខ ១១២៩ និងផ្លូវលេខ ១៩៣០ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ ប្រអប់សំបុត្រលេខ ៖១៥៨៧ , ទូរស័ព្ទ: (៨៥៥-២៣) ៨៦៤ ០៧៨
ទូរសារ: (៨៥៥-២៣) ៨៦៤ ០៧៦, E-mail: info@bakc.org.kh, website: www.bakc.org.kh

**ប្រការ ២ .-** - រាល់ទំនាក់ទំនង និង គ្រប់លិខិតរបស់កម្មសិក្សាការី ដែលធ្វើឡើងក្នុងក្របខ័ណ្ឌប្រកបវិជ្ជាជីវៈរបស់ខ្លួន ត្រូវមានហត្ថលេខាយល់ព្រមពីគ្រូកម្មសិក្សា។

- គ្រប់ការងារកម្មសិក្សារបស់កម្មសិក្សាការី ស្ថិតនៅក្រោមការគ្រប់គ្រង និងទទួលខុសត្រូវផ្ទាល់របស់គ្រូកម្មសិក្សា។
- ចប់រយៈពេលកម្មសិក្សា កម្មសិក្សាការី ត្រូវធ្វើរបាយការណ៍អំពីលទ្ធផលការងាររបស់ខ្លួន ដោយភ្ជាប់មកជាមួយនូវឯកសារសំអាងទាំងអស់ សម្រាប់ដាក់ជូនក្រុមប្រឹក្សាគណៈមេធាវី ពិនិត្យ និងសម្រេច។

**ប្រការ ៣ .-** កម្មសិក្សាការីត្រូវចូលរួមក្នុងវគ្គបណ្តុះបណ្តាលនានារបស់គណៈមេធាវី និងចូលរួមគ្រប់សកម្មភាពដែលចាត់តាំងដោយគណៈមេធាវី។

**ប្រការ ៤ .-** បទប្បញ្ញត្តិទាំងឡាយដែលមានខ្លឹមសារផ្ទុយពីសេចក្តីសម្រេចនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ៥ .-** អគ្គលេខាធិការ អគ្គហេរញ្ញិក និងសាមីខ្លួន ត្រូវអនុវត្តសេចក្តីសម្រេចនេះ តាមមុខការរៀងៗខ្លួន៕

**ចម្លងជូន :**

-ក្រុមប្រឹក្សាគណៈមេធាវី

-ដូចប្រការ ៥

-ឯកសារ-កាលប្បវត្តិ

**មេធាវី.ប៊ុន-ហុន**